ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ២៣៧៤ ព.ណ..ក.ណ.ម

ថ្ងៃអង្គារ ១កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០២៣

## ជម្រាបមក

### លោក/លោកស្រីប្រធានក្រុមហ៊ុន ជេ ស៊ី អិម នីបផន ប្រាយវេត អិលធីឌី

**កម្មវត្ថុ៖** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខលើផលិតផលថ្នាំលាប ថ្នាំវ៉ានីស ថ្នាំលាបដែក ថ្នាំលាបការពារគីង សម្រាប់ទូកកប៉ាល់ និងសំណង់ខួងប្រេង ផលិតផលការពារច្រេះ និងរក្សាសភាពដើមរបស់ឈើ ថ្នាំលាប(បៀក)(ទម្រង់ជាថ្នាំលាប) សម្រាប់ទូកកប៉ាល់ និងសំណង់ខួងប្រេងម៉្យាវ៉ានីសសម្រាប់ការពារ និងកែលម្អផ្ទៃនៃផលិតផលធ្វើពីដែក ប្លាស្ទិច ឈើកិន ឬឈើម៉ាក "NIPPON PAINT" របស់ក្រុមហ៊ុន **ជេ ស៊ី អិម នីបផន ប្រាយវេត អិលធីឌី** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង៖** - មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

-លិខិតស្នើសុំរបស់ក្រុមហ៊ុន **ជេ ស៊ី អិម នីបផន ប្រាយវេត អិលធីឌី** ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២

- លិខិតប្រគល់សិទ្ធិផ្ដាច់មុខរបស់ក្រុមហ៊ុន Nippon Paint Holdings SG PTE. LTD. ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០២២

- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៥៩៤៨/០២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានក្រុមហ៊ុនថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខលើផលិតផលថ្នាំលាប ថ្នាំវ៉ានីស ថ្នាំលាបដែក ថ្នាំលាបការពារគីង សម្រាប់ទូក កប៉ាល់ និងសំណង់ខួងប្រេង ផលិតផលការពារច្រេះ និងរក្សាសភាពដើមរបស់ឈើ ថ្នាំលាប(បៀក)(ទម្រង់ជាថ្នាំលាប) សម្រាប់ ទូកកប៉ាល់ និងសំណង់ខួងប្រេងម៉្យាវ៉ានីសសម្រាប់ការពារ និងកែលម្អផ្ទៃនៃផលិតផលធ្វើពីដែក ប្លាស្ទិច ឈើកិន ឬឈើពាក់ម៉ាកខាងលើរបស់ក្រុមហ៊ុន **ជេ ស៊ី អិម នីបផន ប្រាយវេត អិលធីឌី** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន Nippon Paint Holdings SG PTE. LTD. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រា និងតម្កល់សិទ្ធិផ្ដាច់មុខនេះមានសុពលភាព ០២ (ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Nippon Paint Holdings SG PTE. LTD. ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រា និងតម្កល់សិទ្ធិផ្ដាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្ដាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោកប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

*ចម្លងជូន:*
- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្ដេចអគ្គមហាសេនាបតីតេជោ**នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេចក្រឡាហោម**ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប.)*
- *អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ -កាលប្បវត្តិ*